Hong Leong Bank



# គោលនយោបាយ ស្តីពី វីស្សលប្លូវីង

ខែមីនា ឆ្នាំ២០២៦

[redacted]

# មាតិកា


ទំព័រទី ០៣ គោលបំណង

ទំព័រទី ០៤ វិសាលភាព

ទំព័រទី ០៥ សេចក្តីថ្លែងការណ៍គោលនយោបាយ

ទំព័រទី ០៦ គោលការណ៍

ទំព័រទី ០៧ នីតិវិធី

ទំព័រទី ០៩ ការការពារអ្នករាយការណ៍វីស្យលប្លូវីង

ទំព័រទី ១០ ឯកសារយោង

Hong Leong Bank





# ១. គោលបំណង

ដើម្បីផ្តល់មធ្យោបាយ និងការការពារដល់និយោជិតទាំងអស់របស់ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី ("ធនាគារ") និង បុគ្គលណាមួយ (រូបវន្តបុគ្គល ឬនីតិបុគ្គល) រួមទាំងអ្នកដែលផ្តល់សេវាកម្ម ឬមានទំនាក់ទំនងអាជីវកម្មជាមួយ ធនាគារ ក្នុងការរាយការណ៍ដោយសម្ងាត់អំពីការប្រព្រឹត្ត ឬសកម្មភាពមិនត្រឹមត្រូវ ណាមួយដែលមានពាក់ព័ន្ធនឹង ធនាគារ និង/ឬ បុគ្គលពាក់ព័ន្ធជាមួយធនាគារ តាមរយៈ បណ្តាញនៃការរាយការណ៍វីស្សលប្លូវីងរបស់ធនាគារ។

គោលនយោបាយនេះគឺជាកម្មសិទ្ធិរបស់ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី (ហៅកាត់ថា "ធនាគារ") ហើយត្រូវតែចាត់ទុកជាការសម្ងាត់កម្រិតខ្ពស់។ គ្មានផ្នែកណាមួយនៃគោលនយោបាយនេះអាចត្រូវបានផលិតឡើងវិញ រក្សាទុកក្នុងទម្រង់ណាមួយ ឬដោយមធ្យោបាយណាមួយមិនថា មេកានិក អេឡិចត្រូនិច ការថតចម្លងផ្សេងៗក្តី ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីគណៈគ្រប់គ្រងរបស់ ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី ("ធនាគារ") ឡើយ។

# ២. វិសាលភាព

២.១ គោលនយោបាយនេះ អនុវត្តចំពោះនិយោជិតរបស់ធនាគារ។

២.២ លក្ខខណ្ឌតម្រូវណាមួយដែលតឹងរ៉ឹងជាង រវាងគោលនយោបាយនេះ និងរាល់បទប្បញ្ញត្តិជាធរមានចេញដោយអាជ្ញាធរគឺត្រូវបានអនុវត្ត។ នៅក្នុងករណីដែលនយោបាយក្រុមប្រឹក្សាភិបាលរបស់ ធនាគារមេ មានភាពតឹងរ៉ឹងជាង និងមិនអាចអនុវត្តបាន ហេតុផលនៃការមិនអាចអនុវត្តបានត្រូវតែមានការស្នើសុំការឯកភាពពីម្ចាស់គោលនយោបាយក្រុមប្រឹក្សាភិបាល។



២.៣ បុគ្គលដែលរៀបរាប់ខាងក្រោមអាចលើកឡើងនូវការប្រព្រឹត្តមិនត្រឹមត្រូវ ឬទង្វើខុសឆ្គងដែលបានរកឃើញតាមរយៈបណ្តាញរាយការណ៍វិស្សលប្លូវីងរបស់ធនាគារ៖

ក.និយោជិត ឬ ក្រុមប្រឹក្សាភិបាលរបស់ ធនាគារ និង

ខ.រូបវន្តបុគ្គល ឬនីតិបុគ្គលរួមទាំងអ្នកដែលផ្តល់សេវាកម្ម ឬមានទំនាក់ទំនងអាជីកម្មជាមួយ ធនាគារ។

# ៣. សេចក្តីថ្លែងការណ៍គោលនយោបាយ

គុណតម្លៃជាមូលដ្ឋានរបស់ធនាគារ គឺ យើង"នៅទីនេះសម្រាប់រយៈពេលវែង"។ ក្នុងការប្រកាន់ខ្ជាប់នូវគុណតម្លៃនេះ ធនាគារប្តេជ្ញាចំពោះស្តង់ដារវិជ្ជាជីវៈ និងក្រមសីលធម៌ខ្ពស់ក្នុងការអនុវត្តសកម្មភាពអាជីវកម្ម និងវិជ្ជាជីវៈរបស់យើងដែលមានចែងក្នុងក្រមសីលធម៌វិជ្ជាជីវៈ ("ក្រម") របស់ធនាគារ។ បុគ្គលទាំងអស់ត្រូវបានលើកទឹកចិត្ត ឱ្យលើកឡើងនូវបញ្ហាដែលពាក់ព័ន្ធនឹងធនាគារ និង/ឬ បុគ្គលដែលពាក់ព័ន្ធ តាមរយៈបណ្តាញរាយការណ៍ណាមួយដែលអាចធ្វើទៅបាន ងាយស្រួល និងឆាប់រហ័ស អំពីការប្រព្រឹត្តមិនត្រឹមត្រូវណាមួយ ដែលអាចមានធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ និងទំនុកចិត្តរបស់សារធារណជនចំពោះធនាគារ។

រាល់កង្វល់ទាំងឡាយគួរតែការលើកឡើងឱ្យបានឆាប់រហ័ស និងសមស្របតាមរយៈបណ្តាញនៃការរាយការណ៍ដែលបានបញ្ជាក់នៅក្នុងគោលនយោបាយក្រុមប្រឹក្សាភិបាល ស្តីពី វិស្សលប្លូវីង ឬតាមរយៈនីតិវិធីរាយការណ៍ផ្ទៃក្នុងរបស់គោលនយោបាយក្រុមប្រឹក្សាភិបាលស្តីពីការប្រតិបត្តិតាម(សម្រាប់និយោជិត)។



# ៤. គោលការណ៍

៤.១ អ្នកត្រូវតែហ៊ាននិយាយ ប្រសិនបើអ្នកជាសាក្សី ឬប្រសិនបើអ្នកត្រូវបានគេណែនាំឱ្យអនុវត្តនូវសកម្មភាពខុសច្បាប់ ឬគ្មានសីលធម៌ រួមទាំងការប្រព្រឹត្តិខុសដោយតតីយភាគី (ដូចជាអតិថិជន អ្នកផ្គត់ផ្គង់ទំនិញ/ផលិតផល ឬដៃគូអាជីវកម្ម)។

៤.២ ការរាយការណ៍របស់អ្នកនឹងត្រូវបានរក្សាការសម្ងាត់បំផុត ហើយនឹងត្រូវបានចែករំលែកតែក្នុងករណីចាំបាច់ ឧទាហរណ៍ជាមួយអ្នកដែលពាក់ព័ន្ធក្នុងការស៊ើបអង្កេត ការដោះស្រាយ ឬការកែតម្រូវបញ្ហា។

៤.៣ រាល់កង្វល់ទាំងឡាយដែលអាចត្រូវបានលើកឡើង តាមរយៈវិស្សលប្លូវីង គួរតែជាកង្វល់ពិតប្រាកដអំពីការប្រព្រឹត្តមិនត្រឹមត្រូវ ឬសកម្មភាពខុសឆ្គងដែលអាចជះឥទ្ធិពលមិនល្អដល់ធនាគារ រួមមានជាអាទិ៍៖

ក. រាល់សុចរិតភាព / ភាពស្មោះត្រង់ ឬបទល្មើសព្រហ្មទណ្ឌ រួមទាំងការលួចបន្លំ ការឆបោក ការរំលោភលើទំនុកចិត្ត អំពើពុករលួយ ការសូកប៉ាន់ និងការគំរាមកំហែងហែកកេរ្តិ៍។

ខ. រាល់ការមិនអនុលោមតាមការអនុវត្តច្បាប់ ឬបទប្បញ្ញត្តិនានា

គ. ការរំលោភលើគោលនយោបាយ នីតិវិធី និងបទដ្ឋាននានារបស់ធនាគារ។

ឃ. រាល់អំពើប្រព្រឹត្តមិនត្រឹមត្រូវដែលអាចនឹងទទួលរងនូវទណ្ឌកម្មវិន័យ ឬ

ង. រាល់ទង្វើដែលខុសឆ្គងពីការគ្រប់គ្រងផ្សេងៗរបស់ស្ថាប័ន

៤.៤ សូមចំណាំថារាល់បណ្តឹងណាមួយដែលមានលក្ខណៈបុគ្គល ឬដែលទាក់ទងនឹងការងាររបស់អ្នក គួរតែត្រូវបានលើកឡើងតាមរយៈ បណ្តាញធនធានមនុស្ស (HR) មិនមែនតាមរយៈគោលនយោបាយវិស្សលប្លូវីងនេះ ឬការបំពេញទម្រង់វិស្សលប្លូវីងនោះទេ។

# ៥. នីតិវិធី

៥.១ រាល់ការរាយការណ៍អំពីការប្រព្រឹត្តមិនត្រឹមត្រូវពាក់ព័ន្ធនឹងធនាគារត្រូវតែធ្វើឡើងទៅកាន់បុគ្គលមានសិទ្ធិ តាមរយៈបណ្តាញទំនាក់ទំនងដូចមានចែងខាងក្រោម ឬតាមមធ្យោបាយប្រហាក់ប្រហែលផ្សេងទៀត៖

| ប្រធានគណៈកម្មការគ្រប់គ្រងហានិភ័យ | ប្រធានគណៈកម្មការសវនកម្ម |
|---|---|
| ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី<br>ផ្ទះលេខ ២៨ វុឌ្ឍិវិថីសម្តេចប៉ាន (ផ្លូវលេខ ២១៤) សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី<br>ផ្ទះលេខ ២៨ វុឌ្ឍិវិថីសម្តេចប៉ាន (ផ្លូវលេខ ២១៤) សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| **នាយកផ្នែកប្រតិបត្តិតាម**<br>ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី ផ្ទះលេខ ២៨ វុឌ្ឍិវិថីសម្តេចប៉ាន (ផ្លូវលេខ ២១៤) សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ | |

តាមរយៈសារអេឡិចត្រូនិច: : Whistleblowing@hlbkh.hongleong.com

៥.២ ប្រសិនបើមានការផ្លាស់ប្តូរបុគ្គលមានសិទ្ធិខាងលើ ធនាគារនឹងមានការជូនដំណឹងអំពីការផ្លាស់ប្តូរនេះ។

៥.៣ អ្នករាយការណ៍វីស្សលប្លូវីង ត្រូវបានណែនាំឱ្យធ្វើការរាយការណ៍ជាលាយលក្ខណ៍អក្សរ និងផ្តល់ព័ត៌មានលម្អិតគ្រប់គ្រាន់ដែលរួមមានដូចខាងក្រោម៖

ក. ប្រភេទ ឬការពិពណ៌នាអំពីការប្រព្រឹត្តមិនត្រឹមត្រូវ

ខ. ឈ្មោះរបស់បុគ្គលដែលបានប្រព្រឹត្ត ឬអ្នកចូលរួមក្នុងការប្រព្រឹត្តមិនត្រឹមត្រូវ

គ. បញ្ហាលម្អិតដែលបានលើកឡើង គួររៀបរាប់បញ្ចូលនូវ "កម្មវត្ថុ" "នៅពេលណា" និង "ទីកន្លែងណា" ដែលទាក់ទងនឹងការប្រព្រឹត្តមិនត្រឹមត្រូវ និង

ឃ. ភ្ជាប់ជាមួយឯកសារគាំទ្រ ឬភស្តុតាង ប្រសិនបើមាន។

- ប្រសិនបើអ្នកចង់រាយការណ៍ អ្នកអាចប្រើប្រាស់ ទម្រង់នៃការរាយការណ៍វីស្សលប្លូវីង របស់ធនាគារ ដើម្បីផ្តល់ព័ត៌មានលម្អិតដែលតម្រូវ។

# ៥. នីតិវិធី

៥.៤ អ្នករាយការណ៍វិស្សលប្លូវីង ត្រូវបានលើកទឹកចិត្តឱ្យផ្តល់នូវ ឈ្មោះ លេខទំនាក់ទំនង ដើម្បីឱ្យធនាគារ អាចបញ្ជាក់ ឬទទួលបានព័ត៌មានបន្ថែមក្នុងគោលបំណងស៊ើបអង្កេតបន្ថែមទៀតនៃការប្រព្រឹត្តមិនត្រឹមត្រូវ។

៥.៥ ចំពោះអ្នកដែលជ្រើសរើសយកការមិនបញ្ចេញឈ្មោះ/ដោយអនាមិក សូមមេត្តាជ្រាបថា ធនាគារមានសមត្ថភាព ក្នុងការស៊ើបអង្កេតអំពីការប្រព្រឹត្តមិនត្រឹមត្រូវត្រឹមកម្រិតនៃការរៀបរាប់ក្នុងរបាយការណ៍ ដែលទទួលបានដោយធនាគារប៉ុណ្ណោះ។ នៅពេលផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ ធនាគាររក្សាសិទ្ធិមិនស៊ើបអង្កេតការប្រព្រឹត្តមិនត្រឹមត្រូវ ដែលត្រូវបានលើកឡើងដោយអនាមិក ដោយសារតែកង្វះលទ្ធភាពក្នុងការស្វែងរកការបំភ្លឺដើម្បីបញ្ជាក់ការពិតដែលពាក់ព័ន្ធសម្រាប់គោលបំណងស៊ើបអង្កេត ។

៥.៦ ម្យ៉ាងទៀត អ្នករាយការណ៍វិស្សលប្លូវីងក៏អាចរាយការណ៍ដោយផ្ទាល់ទៅកាន់មន្ត្រីរាជរដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងភ្នាក់ងារអនុវត្តច្បាប់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចជា ធនាគារជាតិនៃកម្ពុជា ឬអង្គភាពប្រឆាំងអំពើពុករលួយ ឬក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទការងារ ឬនគរបាល។ល។

# ៦. ការការពារអ្នករាយការណ៍ វិស្សលប្លូវីង

៦.១ យោងតាមកថាខណ្ឌ ៦.២ និងកម្រិតដែលត្រូវបានអនុញ្ញាតដោយច្បាប់ អ្នកនឹងត្រូវបានការពារពីការគុំគួន ចំណាត់ការធ្ងន់ធ្ងរចំពោះការងារ ឬចំណាត់ផ្លូវច្បាប់ និងពីការបង្ហាញពីអត្តសញ្ញាណរបស់អ្នក ប្រសិនបើការរាយការណ៍របស់អ្នកត្រូវបានធ្វើឡើងដោយភាពស្មោះត្រង់ (បើទោះបីជាអ្នកត្រូវបានគេយល់ឃើញថាមានការភាន់ច្រឡំចំពោះការរាយការណ៍ដែលអ្នកបានលើកឡើងក៏ដោយ)។

៦.២ ការការពាររបស់អ្នកអាចនឹងត្រូវលុបចេញវិញ ហើយអ្នកអាចនឹងត្រូវប្រឈមនឹងវិធានការណាមួយប្រសិនបើ៖

- អ្នកចូលរួមប្រព្រឹត្តអំពីមិនត្រឹមត្រូវណាមួយដែលបានរកឃើញ
- អ្នកបានបង្កើតសេចក្តីថ្លែងការណ៍ដែលអ្នកបានដឹង ឬជឿថាមិនពិត ឬមិនជឿថាជាការពិត
- ការរាយការណ៍ពីការប្រព្រឹត្តមិនត្រឹមត្រូវដែលគ្មានគោលបំណងច្បាស់លាស់ និងមិនសមហេតុផល ឬដែលគ្មានមូលដ្ឋានជាការរាយការណ៍ ដែលមានលក្ខណៈជាការព្យាបាទ
- ការរាយការណ៍ដែលធ្វើឡើងសម្រាប់តែគោលបំណង ឬដោយមានចេតនាចៀសវាងពីការបណ្តេញចេញពីការងារ ឬគេចវេសពីវិធានវិន័យផ្សេងៗ។

៦.៣ ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីសកម្មភាពគុំគួន/សងសឹកដែលអាចកើតមាន ឬ ចំណាត់ការការងារបែបអវិជ្ជមាន អ្នកអាចរាយការណ៍ទៅ នាយកផ្នែកធនធានមនុស្ស នាយកបគ្រប់គ្រង និង/ឬប្រធានគណៈកម្មការសវនកម្ម ឬ ប្រធានគណៈកម្មការគ្រប់គ្រងហានិភ័យ តាមរយៈបណ្តាញ វិស្សលប្លូវីង របស់ ធនាគារ។

# ៧ .ឯកសារយោង

គោលនយោបាយនេះត្រូវបានរួមបញ្ចូលនូវតម្រូវការផ្ទៃក្នុងរបស់ ធនាគារ ក៏ដូចជាកាតព្វកិច្ចអនុលោមតាមបទប្បញ្ញត្តិពី៖

- ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (១៩៩៩)
- ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ (២០១០)
- ប្រកាសស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ របស់ធនាគារជាតិនៃកម្ពុជា
- ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានា។

# ទម្រង់នៃការរាយការណ៍វិស្សលប្លូវីង

អ្នកអាចរាយការណ៍វិស្សលប្លូវីង អំពីការប្រព្រឹត្តមិនត្រឹមត្រូវណាមួយដែលកើតឡើង នៅក្នុង ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី។ ប្រសិនបើការរាយការណ៍របស់អ្នក គឺទាក់ទងនឹងបញ្ហាមុខតំណែងផ្ទាល់ខ្លួន ឬការងាររបស់អ្នក សូមរាយការណ៍ទៅកាន់នាយកដ្ឋានធនធានមនុស្សប៉ុន្តែមិនគួររាយការណ៍តាមរយៈទម្រង់របាយការណ៍វិស្សលប្លូវីងនេះទេ។

| | |
|---|---|
| ទំនាក់ទំនងជាមួយធនាគារ<br>YOUR RELATIONSHIP WITH HONG LEONG | សូមជ្រើសរើស៖<br>Please tick all applicable:<br>អតិថិជន<br>Customer: □<br>និយោជិត<br>Employee: □ |
| | ផ្សេងៗ៖<br>OTHER:<br>សូមបញ្ជាក់ពីទំនាក់ទំនងរបស់អ្នក។<br>សូមផ្តល់ព័ត៌មានលម្អិតរបស់និយោជករបស់អ្នក ប្រសិនបើនិយោជករបស់អ្នកផ្តល់សេវាកម្ម ឬមានទំនាក់ទំនងអាជីវកម្មជាមួយ ធនាគារ។<br>Please specify your relationship.<br>Please include your employer´s details if your employer provides services to or otherwise has a business relationship with Hong Leong. |

| | |
|---|---|
| ប្រភេទគណនី<br>(សម្រាប់អតិថិជន)<br><br>ACCOUNT TYPE(S)<br>(For customers) | សូមជ្រើសរើសប្រភេទគណនីដែលត្រឹមត្រូវ៖<br>Please tick all applicable types:<br><br>គណនីចរន្ត<br>Current account: □<br>គណនីសន្សំ<br>Savings account: □<br>កម្ចី<br>Loan: □<br>ឥណទានបុគ្គល<br>Mortgage: □<br><br>ផ្សេងៗ៖<br>OTHER:<br>សូមបញ្ជាក់ផលិតផល ឬ សេវាកម្មដែលធនាគារផ្តល់ជូនអ្នក។<br>Please specify Hong Leong products/services which are provided to you. |
| អត្តលេខបុគ្គលិករបស់អ្នក<br>(ប្រសិនបើអ្នកជាបុគ្គលិកធនាគារ)<br>YOUR STAFF ID<br>(If you are a Hong Leong Bank staff) | |
| ព័ត៌មានលម្អិតរបស់អ្នក<br><br>YOUR CONTACT DETAILS | ឈ្មោះ<br>Full Name:<br>អាសយដ្ឋាន<br>Address:<br><br>លេខទូរស័ព្ទ<br>Telephone:<br>អ៊ីម៉ែល<br>Email: |

ព័ត៌មានលម្អិតអំពីការរាយការណ៍របស់អ្នក
(សូមផ្តល់ព័ត៌មានឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន)
DETAILS OF YOUR CONCERNS:
(please provide as much information as possible)

ការពិពណ៌នាអំពីការប្រព្រឹត្តមិនត្រឹមត្រូវ៖
(អ្នកអាចបំពេញព័ត៌មានបន្ថែមនៅទំព័របន្ទាប់ ប្រសិនបើចាំបាច់)

DESCRIPTION OF IMPROPER CONDUCT:

(use the additional information sheet, if necessary)

តើការប្រព្រឹត្តមិនត្រឹមត្រូវកើតឡើងនៅកន្លែងណា?
WHERE DID THE IMPROPER CONDUCT OCCUR?

តើការប្រព្រឹត្តមិនត្រឹមត្រូវកើតឡើងនៅពេលណា?
WHEN DID THE IMPROPER CONDUCT OCCUR?

ឈ្មោះ និង មុខតំណែងអ្នកដែលពាក់ព័ន្ធ៖
NAME AND POSITION OF PERSON(S) INVOLVED:

ព័ត៌មានលម្អិតរបស់សាក្សី៖
DETAILS OF ANY WITNESS(ES):

តើអ្នកបានរាយការណ៍ពីការប្រព្រឹត្តមិនត្រឹមត្រូវនេះទៅអាជ្ញាធរមានសមត្ថកិច្ចដែរឬទេ? ប្រសិនបើបានរាយការណ៍ សូមផ្តល់ព័ត៌មានលម្អិត៖

DID YOU REPORT THE IMPROPER CONDUCT TO ANY AUTHORITIES? IF YES, PLEASE GIVE DETAILS:

ភ្ជាប់ឯកសារគាំទ្រ មាន □ មិនមាន □
SUPPORTING DOCUMENT(S) ATTACHED (Please tick)? Yes □ No □

ព័ត៌មានបន្ថែម

ADDITIONAL INFORMATION SHEET

ព័ត៌មានបន្ថែមផ្សេងៗ៖

ANY ADDITIONAL INFORMATION:

សូមផ្តល់ព័ត៌មានផ្សេងទៀតប្រសិនបើអ្នកគិតថាអាចមានជាប់ពាក់ព័ន្ធ ឧទាហរណ៍ ថាតើអ្នកបានទៅជួបបុគ្គលដែលពាក់ព័ន្ធ ថាតើវាមានផលប៉ះពាល់ហិរញ្ញវត្ថុណាមួយចំពោះធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី ជាដើម។

Provide any further details you think may be relevant, for example, whether you approached the person(s) concerned, any financial impact to the Hong Leong Bank (Cambodia) PLC, etc.

Hong Leong Bank




# WHISTLEBLOWING POLICY

Version  March 2026

Hong Leong Islamic Bank

Hong Leong Bank

# TABLE OF CONTENTS


| | |
|---|---|
| PAGE 03 | PURPOSE |
| PAGE 04 | SCOPE |
| PAGE 05 | POLICY STATEMENT |
| PAGE 06 | PRINCIPLES |
| PAGE 07 | PROCEDURES |
| PAGE 09 | WHISTLEBLOWER PROTECTION |
| PAGE 10 | REFERENCE |



# 1. PURPOSE

To provide an avenue for all employees of Hong Leong Bank (Cambodia) PLC. (“HLBCAM”), and any (legal or natural) person including those providing services to, or having a business relationship with HLBCAM, to raise genuine concerns about any improper conduct or wrongful act (“Improper Conduct”) that is committed involving HLBCAM and/or persons associated with HLBCAM (Associated Persons) through the HLBCAM’s whistleblowing channel on a confidential basis.

This Policy is the property of HLBCAM and must be treated as highly confidential. No part of this Policy may be reproduced, stored in any form or by any means, mechanical, electronic, photocopying, recording or otherwise without written permission from the management of HLBCAM.

# 2. SCOPE

2.1 The Board Policy on Whistleblowing ("Whistleblowing Policy" or "this Policy") applies to HLBCAM.

2.2 The more stringent requirement between this Policy and that issued by the relevant local regulatory bodies are to be adopted. In the event the HLBB Board Policy is more stringent and cannot be observed, the reasons for non-observation must be subject to acceptance by the HLBB Board Policy Owner, and the variation to this Policy must be subject to approval by the HLBB Board Policy Owner.





2.3 The following person may raise any genuine concerns about any Improper Conduct via HLBCAM's whistleblowing channel:

a. Any employee or director of HLBCAM; and
b. Any (legal or natural) person, including persons providing services to, or having a business relationship with, HLBCAM.

# 3. POLICY STATEMENT

A fundamental value of HLBCAM is that we are 'Here for the Long Term'. In upholding this value, HLBCAM commits to a high standard of professionalism and ethics in the conduct of our business and professional activities as set out in the HLBCAM's Code of Conduct & Ethics ("Code"). All persons are encouraged to raise genuine concern about any actual or potential Improper Conduct involving HLBCAM and/or Associated Person that compromises these aspirations and consequently have the potential to tarnish HLBCAM's reputation and community standing. Such genuine concerns should be raised at the earliest opportunity and in an appropriate way, through available channels provided under this HLBCAM Board Policy on Whistleblowing, or following the internal escalation process as provided under the HLBCAM's Board Policy on Compliance (for employees).





# 4. PRINCIPLES

4.1 You must speak up if you witness or if you are improperly instructed or advised to carry out illegal or unethical act, including wrongdoing by third parties (such as customers, vendors or business partners).

4.2 Whistleblower report will be treated with strict confidentiality and only shared where necessary, for example with persons who are involved in investigating, resolving, or remediating the issue.

4.3 Concerns that may be raised through whistleblowing should be the genuine concerns about any Improper Conduct involving HLBCAM and/or that may adversely impact HLBCAM, including but not limited to:

a. Any integrity/ honesty or criminal offences, including fraud, theft, criminal breach of trust, corruption, bribery and blackmail;
b. Any failure to comply with legal or regulatory obligations;
c. Violations of HLBCAM's Policies, Procedures and Standards;
d. Any Improper Conduct which would be a disciplinary offence; or
e. Any gross mismanagement of company affairs.

4.4. Please note that any grievance of a personal nature or that related to your employment should be raised through Human Resources (HR) channel and not through this whistleblowing policy or the whistleblower form.

# 5. PROCEDURES

5.1 Any disclosure of Improper Conduct that concerns HLBCAM must be made to any of the relevant Designated Person through the communication channels as set out below HLBCAM's whistleblowing channel or other equivalent channels:

| Chairman of the Board Risk Management Committee | Chairman of the Board Audit Committee |
|---|---|
| Hong Leong Bank (Cambodia) PLC. #28, Samdech Pan Avenue (St.214), Sangkat Boeung Raing, Khan Daun Penh, Phnom Penh | Hong Leong Bank (Cambodia) PLC. #28, Samdech Pan Avenue (St.214), Sangkat Boeung Raing, Khan Daun Penh, Phnom Penh |
| **Head of Compliance (Compliance officer)**<br>Hong Leong Bank (Cambodia) PLC. #28, Samdech Pan Avenue(St.214), Sangkat Boeung Raing, Khan Daun Penh, Phnom Penh | |

via email address: Whistleblowing@hlbkh.hongleong.com

5.2 Any changes to Designated Person above will be communicated through issuance of General Circular.

5.3 Whistleblowers are advised to make their disclosures in writing and to provide sufficient details which include the following:

a. the type or description of Improper Conduct;
b. the name of individuals who have committed or are involved in the Improper Conduct;
c. full details of the concern raised, including the 'what', 'when' and 'where' in relation to the improper conduct; and
d. the relevant supporting documents or evidence, if any.

- Should you wish to do so, you may use our Whistleblower Form to provide the details required.

# 5. PROCEDURES

5.4 Whistleblowers are encouraged to provide their full name and contact details, to facilitate HLBCAM to clarify or obtain further information for purposes of further investigation into the Improper Conduct.

5.5 Any person who elect to remain anonymous is advised that HLBCAM's ability to investigate the alleged Improper Conduct is limited to the extent of the contents of the report received by HLBCAM. Where insufficient information is provided, HLBCAM reserves the right not to investigate the alleged Improper Conduct that is raised anonymously, due to inability to seek clarification to ascertain relevant facts for investigation purposes.

5.6 Whistleblowers also have the right to report to relevant government or regulatory authorities and enforcement agencies in Cambodia such as National Bank of Cambodia (NBC), Anti-Corruption Unit (ACU), Arbitration Council on Labour Dispute, Police, etc.

# 6. WHISTLEBLOWER PROTECTION

6.1 Subject to paragraph 6.2 below and to the extent permitted by law, you will be protected from retaliation, adverse employment action or legal action and where feasible, from disclosure of your identity, provided your report is made in good faith (even if you are genuinely mistaken in the concerns you raise).

6.2 Your protection may be revoked and appropriate action may be taken against you if:

a. You have participated in the Improper Conduct disclosed;
b. You made a material statement which you knew or believed to be false or did not believe to be true;
c. the disclosure of the Improper Conduct is frivolous or vexatious;
d. the disclosure of the Improper Conduct is made maliciously; or
e. the disclosure of the Improper Conduct is made solely or substantially with the motive of avoiding dismissal or other disciplinary action.

6.3 If you have concerns about possible retaliatory action or adverse employment action, you may lodge a report to the Head of Human Resources Division, Managing Director and/or the Chairman of the Board Audit Committee for HLBCAM, the Chairman of the Board Risk Management Committee for HLBCAM through the Bank's Whistleblowing Channels.

# 7.REFERNCE

This Policy has been formulated to include HLBCAM's internal requirements as well as regulatory requirements from the following regulatory guidelines:

- Cambodian Law on Banking and Financial Institutions, 1999
- Cambodian Law on Anti-Corruption, 2010
- NBC's Prakas on Internal Control of Banks and Financial Institutions
- Other applicable laws and regulations

# WHISTLEBLOWER FORM

You should raise any genuine concerns about any improper conduct or wrongful act ("Improper Conduct") that is committed within Hong Leong Bank (Cambodia) PLC. Concerns on your personal position or your employment, should be raised through Human Resources (HR) channel, and not through this Whistleblower Form.

| | |
|---|---|
| **YOUR RELATIONSHIP WITH HONG LEONG** | **Please tick all that apply:**<br>**Customer:** ☐<br>**Employee:** ☐ |
| | **OTHER:**<br>**Please specify your relationship. Please include your employer's details if your employer provides services to or otherwise has a business relationship with Hong Leong.** |
| **ACCOUNT TYPE(S) (For customers)** | **Please tick all applicable types:**<br>**Current account:** ☐ **Savings account:** ☐<br>**Loan:** ☐ **Mortgage:** ☐ |
| | **OTHERS:**<br>**Please specify Hong Leong products/services which are provided to you.** |
| **YOUR STAFF ID: (If you are a Hong Leong Bank staff)** | |
| **YOUR CONTACT DETAILS** | **Full Name:**<br><br>**Address:**<br><br>**Telephone:**<br><br>**Email:** |

HongLeong Bank

| DETAILS OF YOUR CONCERNS:<br>(Please provide as much information as possible) |
| --- |
| DESCRIPTION OF IMPROPER CONDUCT:<br>(use the additional information sheet, if necessary) |
| WHERE DID THE IMPROPER CONDUCT OCCUR? |
| WHEN DID THE IMPROPER CONDUCT OCCUR? |
| NAME AND POSITION OF PERSON(S) INVOLVED: |
| DETAILS OF ANY WITNESS(ES): |
| DID YOU REPORT THE IMPROPER CONDUCT TO ANY AUTHORITIES? IF YES, PLEASE GIVE DETAILS: |
| SUPPORTING DOCUMENT(S) ATTACHED (Please tick)? Yes ☐ No ☐ |

| ADDITIONAL INFORMATION SHEET |
| --- |
| **ANY ADDITIONAL INFORMATION:**<br>**Provide any further details you think may be relevant, for example, whether you approached the person(s) concerned, any financial impact to the Hong Leong Bank (Cambodia) PLC , etc.** |